**មាត្រា ១:** តែងតាំងលោកជំទាវ **ផុន ផល្លា** ជាទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣១០.១១៤២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ១១២៦ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១០១៣/១១២៩

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនកញ្ញា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងអ្នកអង្គម្ចាស់ **អនុរក្ស ឈឹមសុហ៊ីន** ជាទីប្រឹក្សាអមក្រសួងកិច្ចការនារី មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣១០.១១៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ១១២៩ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

នស/រកត/១០១៣/១១៧០

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោកជំទាវ **ប្រាក់ ចន្ថា** ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧រស.១៧១០.១១៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣

លេខៈ ១១៤៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១០១៣/១១៧១

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តែងតាំងឯកឧត្តម **ស្លា ប្រយុទ្ធ** ជាទីប្រឹក្សាអមក្រសួងមុខងារសាធារណៈ មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.រ.ស. ១៣១០.១១៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣

លេខ: ១១៧៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១០១៣/១១៧២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តែងតាំងឯកឧត្តម **ផាន់ សុគន្ធ** ជាទីប្រឹក្សាអមរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧. ១៣១០.១១៤៦

លេខ: ១១២២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣

**សយ សុខា**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- តាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់នូវគណនេយ្យភាពរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ននានាដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើមន្ត្រីរាជការស៊ីវិលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលបំពេញការងារនៅថ្នាក់ក្រោមជាតិរួមមាន មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ លើកលែងតែមន្ត្រីរាជការស៊ីវិលនៃអង្គភាពគយ រតនាគារ ពន្ធដារ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈនានា។

## ជំពូកទី២
## គោលការណ៍

**មាត្រា ៤.-**

ការអនុវត្តអំណាច ដែលបានធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការតែងតាំង

ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិតាមស្មារតីនៃអនុក្រឹត្យនេះ ត្រូវផ្អែកលើគោលការណ៍ប្រសិទ្ធភាព ពិគ្រោះយោបល់ តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពរបស់មន្ត្រីរាជការស៊ីវិល ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥ .-**

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ត្រូវផ្អែកទៅលើនីតិវិធី លក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដែលមានកំណត់នៅក្នុងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាធរមាន និងបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះ។

**មាត្រា ៦ .-**

រាល់កិច្ចប្រជុំរបស់គណៈអភិបាល និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីពិភាក្សា និង/ឬអនុម័តលើសំណើសុំតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលតាមស្មារតីនៃអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាសម្ងាត់។

ក្រុមប្រឹក្សាត្រូវធ្វើការអនុម័តលើសំណើសុំតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងណាមួយតាមរយៈការបោះឆ្នោតជាសម្ងាត់។

រាល់កំណត់ហេតុកិច្ចប្រជុំនានាពាក់ព័ន្ធនឹងកិច្ចប្រជុំជាសម្ងាត់នេះ មិនត្រូវផ្សព្វផ្សាយជាសាធារណៈឡើយ។ ក្រុមប្រឹក្សាអាចអនុញ្ញាតឲ្យដកស្រង់ខ្លឹមសារគោលនៃកិច្ចប្រជុំសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលឡើយ។

ក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា និងមន្ត្រីពាក់ព័ន្ធនានាត្រូវថែរក្សាឯកសារនានាពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលដែលត្រូវបានស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចជាឯកសារសម្ងាត់ និងមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈឡើយ។

## ជំពូកទី៣
## អំណាច និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល

### ផ្នែកទី១
### មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ៧ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។ បន្ទាប់ពីបានទទួលការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្តត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើនេះ។

ចំពោះបេក្ខជន ដែលស្នើតែងតាំងត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យ ដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងមហាផ្ទៃ ឬពីសាលារាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្តត្រូវធ្វើការប្រជុំឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។

**មាត្រា ៨.-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនាយកទីចាត់ការហិរញ្ញវត្ថុនៃសាលារាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះមកក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្តត្រូវលើកសំណើនេះមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ការឯកភាពលើសំណើនេះ។

ផ្អែកលើការឯកភាពខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។ ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្ត ដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬស្នើឲ្យអភិបាលរាជធានី ខេត្ត លើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ តាមនីតិវិធីដូចបានកំណត់ក្នុងវាក្យខណ្ឌនានាខាងលើនៃមាត្រានេះ។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុង

គណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

**មាត្រា ៩.-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងខាងលើទៅក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័ត មុននឹងលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលក្រុង ស្រុក ខណ្ឌពុំមានមន្ត្រីដែលមានលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យសមស្របសម្រាប់ការស្នើសុំតែងតាំងក្នុងមុខតំណែងទាំងនេះទេនោះ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីជ្រើសរើសបេក្ខជនដែលមានលក្ខណៈសមស្របពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ផ្អែកតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវពិនិត្យអំពីលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យរបស់មន្ត្រីដែលត្រូវបានស្នើតែងតាំងដោយផ្អែកតាមការកំណត់នៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ករណីបេក្ខជនដែលស្នើសុំតែងតាំងនោះពុំសមស្របនឹងលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដែលបានកំណត់ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជ្រើសរើសបេក្ខជនថ្មីដែលមានលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យសមស្របមកជំនួស។ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើបេក្ខជនថ្មីនេះជូនអភិបាលរាជធានី ខេត្ត។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។ ក្នុងករណីចាំបាច់ អភិបាល

រាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

**មាត្រា ១០ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ មកក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌត្រូវលើកសំណើនេះ មកអភិបាលរាជធានី ខេត្តសាមី ដើម្បីលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការផ្តល់ការឯកភាពលើសំណើនេះ។

ផ្អែកលើការឯកភាពខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។ ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្តដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬស្នើឲ្យអភិបាលរាជធានី ខេត្តសាមីពិភាក្សាជាមួយអភិបាលក្រុង ស្រុក ខណ្ឌសាមីក្នុងការលើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីក្នុងមុខតំណែងនេះ តាមនីតិវិធីដូចបានកំណត់ក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះ។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ក្នុងករណីចាំបាច់អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុនៃការស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីគណៈអភិបាលរាជធានី ខេត្តឯកភាពលើសំណើសុំផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចនេះ អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីផ្ដល់ការឯកភាពលើសំណើនេះ មុននឹងចេញដីកាផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះតាមនីតិវិធីជាធរមាន។

## ផ្នែកទី២

## មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ

**មាត្រា ១១ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យមានសិទ្ធិលើកសំណើតែងតាំង ឬផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្តមករដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីនីមួយៗ។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថាសំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ននោះ ត្រូវចេញប្រកាសផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

**មាត្រា ១២ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត។

ប្រធានមន្ទីរ អង្គភាពសាមី ត្រូវលើកសំណើសម្រាប់ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងទាំងនេះមកអភិបាលរាជធានី ខេត្ត។ អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្តរួមជាមួយនឹងប្រធានមន្ទីរ អង្គភាពសាមីដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្តសាមីអាចស្នើសុំយោបល់ពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ ប្រធានមន្ទីរ អង្គភាពសាមីត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្តអាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើលិខិតជម្រាបជូនប្រធានមន្ទីរ អង្គភាពសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្តដោយមានការឯកភាពពីគណៈអភិបាលត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះ។

ក្នុងករណីដែលមន្ត្រីណាមួយក្នុងមុខតំណែងទាំងនេះ ត្រូវបានរកឃើញថាមានភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ ឬតាមតម្រូវនៃច្បាប់ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវផ្តល់ការណែនាំដល់ប្រធានមន្ទីរ អង្គភាពសាមី ដើម្បីលើក

សំណើផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមកអភិបាលរាជធានី ខេត្ត។ ក្នុងករណីដែលប្រធានមន្ទីរ អង្គភាពសាមីនោះពុំអនុវត្តតាមការណែនាំនេះទេ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនអាចមានសិទ្ធិផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ ដោយពុំចាំបាច់មានសំណើពីប្រធានមន្ទីរ អង្គភាពសាមីនោះឡើយ។

**មាត្រា ១៣ .-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងចាប់ពីថ្នាក់ប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលចុះក្រោមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងទាំងនេះមកអភិបាលរាជធានី ខេត្ត តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ចំពោះសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានការពិគ្រោះយោបល់បន្ថែមជាមួយប្រធានការិយាល័យជំនាញសាមី។

ផ្អែកលើសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់ប្រធានមន្ទីរ អង្គភាពសាមី អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាលរបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំងនេះ ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្របនេះទេ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីក្នុងការស្នើសុំផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័ន ឬពីមន្ទីរ អង្គភាពជំនាញនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌសាមីដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្តដោយមានការឯកភាពពីគណៈអភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

### មាត្រា ១៤ .-

ចំពោះការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៃអង្គភាពរបស់ក្រសួង ស្ថាប័ន ដែលមានមុខងារផ្តល់សេវាគ្របដណ្តប់លើវិសាលភាពដែនដីនៃរដ្ឋបាលថ្នាក់ក្រោមជាតិលើសពីមួយ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលអង្គភាពនោះមានការិយាល័យតាំងនៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន និងប្រធានអង្គភាពសាមី ត្រូវអនុវត្តតាមនីតិវិធីនានាដូចបានកំណត់នៅក្នុងមាត្រា១១ មាត្រា១២ និងមាត្រា១៣នៃអនុក្រឹត្យនេះ ដោយមានការពិគ្រោះយោបល់ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលពាក់ព័ន្ធ។

### មាត្រា ១៥ .-

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្នុងមុខតំណែងផ្សេងទៀតដែលពុំបានចែងនៅក្នុងមាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ និងមាត្រា១៤នៃអនុក្រឹត្យនេះ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤
## ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការគាំទ្រ

### មាត្រា ១៦ .-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងក្រសួងមុខងារសាធារណៈ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដើម្បីរៀបចំនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តអំណាចដែលបានធ្វើប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ដើម្បីធានាថា ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់អនុវត្តអំណាចក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីដោយអនុលោមទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងធានាឲ្យបាននូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពនៃមន្ត្រីរាជការស៊ីវិល។

គ.ជ.អ.ប. ត្រូវធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល០៦ខែម្តងៗអំពីការអនុវត្តអនុក្រឹត្យនេះ។

**មាត្រា ១៧ .-**

អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលតាមគោលការណ៍នៃអនុក្រឹត្យនេះមកក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីរបស់មន្ត្រីដែលបានតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ដើម្បីពិនិត្យនីត្យានុកូលភាព និងបំពេញបែបបទពាក់ព័ន្ធនឹងប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ការងារក្របខ័ណ្ឌ និងការធានាការអនុវត្តតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យនីត្យានុកូលភាព ប្រសិនបើពិនិត្យឃើញថា ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចនេះធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវធ្វើលិខិតណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះឲ្យធ្វើការកែតម្រូវឲ្យបានត្រឹមត្រូវឡើងវិញ។

ករណីរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនអនុវត្តតាមការណែនាំនេះ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើអន្តរាគមន៍ដោយចេញប្រកាសលុបចោលដីកាដែលធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាននោះជាបន្ទាន់។

**មាត្រា ១៨ .-**

ក្នុងការអនុវត្តអំណាចប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ននានាដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ អាចពិគ្រោះយោបល់ជាមួយ គ.ជ.អ.ប. ដើម្បីចេញសេចក្តីណែនាំបន្ថែមតាមការចាំបាច់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩ .-**

មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានតែងតាំងក្នុងមុខតំណែងណាមួយនៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែង និងបំពេញការងាររហូតដល់មានតម្រូវការនៃការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចក្នុងមុខតំណែងនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.

**ស ខេង**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២១*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦៥៩,១៨ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣១៤ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៧៨អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៦៥៩,១៨ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៦២៦,៥៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៣២,៥៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី ១ និងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣១៨គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៥០៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ១១២,២៤ ហិកតា ចេញពីដែនដីគម្របព្រៃឈើ ឆ្នាំ២០០២ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១០៨,៦៦ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែង ចំនួន ១២ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ៣,៥៨ ហិកតា នៅភូមិមន្ទាយរកោ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ




តារាងចំណុចនិយាមការ

| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តំបន់ I | | | តំបន់ II | | | 31 | 403106 | 1260930 | 47 | 402402 | 1261150 | 63 | 402255 | 1261830 | 78 | 400970 | 1261970 |
| 1 | 403790 | 1261290 | 16 | 403092 | 1262070 | 32 | 403031 | 1260830 | 48 | 402383 | 1261150 | 64 | 402519 | 1261980 | 79 | 400852 | 1261900 |
| 2 | 403709 | 1261230 | 17 | 403119 | 1261630 | 33 | 402963 | 1260820 | 49 | 402375 | 1261190 | 65 | 402677 | 1262060 | 80 | 400657 | 1261750 |
| 3 | 403688 | 1261210 | 18 | 403107 | 1261510 | 34 | 402976 | 1260750 | 50 | 402355 | 1261180 | 66 | 402795 | 1262030 | 81 | 400577 | 1261740 |
| 4 | 403590 | 1261210 | 19 | 403090 | 1261400 | 35 | 402944 | 1260730 | 51 | 402333 | 1261230 | 67 | 402838 | 1262060 | 82 | 400488 | 1261740 |
| 5 | 403561 | 1261240 | 20 | 403063 | 1261360 | 36 | 402928 | 1260710 | 52 | 402314 | 1261230 | 68 | 402842 | 1262150 | 83 | 400475 | 1261820 |
| 6 | 403546 | 1261260 | 21 | 403061 | 1261320 | 37 | 402898 | 1260710 | 53 | 402232 | 1261320 | 69 | 402963 | 1262110 | 84 | 400686 | 1261890 |
| 7 | 403527 | 1261280 | 22 | 403031 | 1261320 | 38 | 402894 | 1260750 | 54 | 402282 | 1261370 | តំបន់ III | | | 85 | 400712 | 1261930 |
| 8 | 403481 | 1261290 | 23 | 403005 | 1261290 | 39 | 402842 | 1260750 | 55 | 402282 | 1261390 | 70 | 401512 | 1261980 | 86 | 400689 | 1262050 |
| 9 | 403492 | 1261340 | 24 | 402988 | 1261250 | 40 | 402832 | 1260790 | 56 | 402213 | 1261570 | 71 | 401504 | 1261870 | 87 | 400701 | 1262090 |
| 10 | 403562 | 1261330 | 25 | 402986 | 1261200 | 41 | 402884 | 1260820 | 57 | 402208 | 1261600 | 72 | 401498 | 1261740 | 88 | 400720 | 1262160 |
| 11 | 403556 | 1261320 | 26 | 403006 | 1261170 | 42 | 402856 | 1260850 | 58 | 402221 | 1261650 | 73 | 401427 | 1261750 | 89 | 400770 | 1262160 |
| 12 | 403564 | 1261300 | 27 | 403061 | 1261080 | 43 | 402770 | 1260810 | 59 | 402212 | 1261710 | 74 | 401352 | 1261780 | 90 | 401066 | 1262100 |
| 13 | 403633 | 1261290 | 28 | 403125 | 1261040 | 44 | 402573 | 1261000 | 60 | 402170 | 1261730 | 75 | 401212 | 1261810 | 91 | 401085 | 1262080 |
| 14 | 403704 | 1261290 | 29 | 403141 | 1261020 | 45 | 402467 | 1261090 | 61 | 402161 | 1261820 | 76 | 401152 | 1261860 | 92 | 401187 | 1262070 |
| 15 | 403755 | 1261290 | 30 | 403140 | 1260980 | 46 | 402434 | 1261110 | 62 | 402251 | 1261800 | 77 | 401072 | 1261980 | 93 | 401267 | 1262050 |

ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ...៥០៥.....អនក្រ.បក...............ចុះថ្ងៃទី០៤.....ខែ.វិច្ឆិកា..ឆ្នាំ២០១៣ ស្ដីពីការកាត់ឆ្វៀលដីសម្បទានដីសេដ្ឋកិច្ច ដែលមានផ្ទៃដីសរុបទំហំ ៥៤៦,៩៤ ហិកតា ចេញពីដែនដីតំបន់ព្រៃឈើ ឆ្នាំ២០០២ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៥១៧,៩៣ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងជាប់ជុះជាក់ស្ដែង ចំនួន ៣០២ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ២៩,០១ ហិកតា នៅភូមិចន្លាយរកា ឃុំត្រាំងជីទាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦អនក្រ.បក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ១០១៨សហវ.ប្រក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមគណនីនិងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាមិនមែនកម្មវិធីចំនួន ៥៩២ ០០០ ០០០រៀល របស់ក្រសួងអប់រំ យុវជន និងកីឡា(ផ្នែកអប់រំ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ពីជំពូក៦៥ (ឧបត្ថម្ភធន និងជំនួយសង្គម) មកជំពូក៦១ (សេវាខាងក្រៅ) ចំនួន ១៣០ ០០០ ០០០រៀល និង ជំពូក៦២ ចំនួន ៤៦២ ០០០ ០០០រៀល ។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទៃក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែង របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កាត់ ចន់**

**ឃាត់ ឈន់ រ៉ែលមុនីវ័ន្ត**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
-រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥១១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

### ការកាត់ដីសរុបទំហំ ២៣៤,៦៤ ហិកតា នៅស្រុករវៀង ខេត្តព្រះវិហារ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដី សម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គីមជាឆូន គ្រុប ខូ អិលធីឌី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៧៣/១៣ គ.គ្រ.ដ.រ.ខ ចុះថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ២៣៤,៦៤ ហិកតា ដែលក្នុងនោះ (១) ទំហំ ១៤,៧៥ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង (២) ទំហំ ២១៩,៨៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គឹមជាធូន គ្រុប ខូ អិលធីឌី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិចំបក់ផ្អែម ឃុំរស្មី ស្រុករវៀង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង (២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៣៧ គ្រួសារ នៅភូមិចំបក់ផ្អែម ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ ។

ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស មានទីតាំងបំពេញការងារនៅក្រសួងមុខងារសាធារណៈ និងប្រើប្រាស់ត្រា, ធនធាន និងមធ្យោបាយសម្ភារៈរបស់ក្រសួងមុខងារសាធារណៈ សម្រាប់ដំណើរការការងារ។

**ប្រការ៤.-**

ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស មានតួនាទី និងភារកិច្ច ចម្បងៗដូចខាងក្រោម÷

- សិក្សាប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលជាលក្ខណៈកញ្ចប់ដោយគ្របដណ្តប់ទាំងមន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ, យោធា, នគរបាលជាតិ, និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ
- លើកសំណើអំពីការកែទម្រង់ប្រព័ន្ធបៀវត្សជាលក្ខណៈកញ្ចប់ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រ សម្រាប់ការដាក់ឱ្យអនុវត្តផែនការកែទម្រង់ប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០១៤-២០១៨ ជូនរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគោរពជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- បំពេញការងារផ្សេងៗទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥.-**

សមាសភាពតំណាងពីក្រសួងនីមួយៗក្នុងក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៦.-**

ប្រធានក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់, មន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នផ្សេងៗ និងទីប្រឹក្សា ឬ អ្នកជំនាញការជាតិ និងអន្តរជាតិ មកប្រជុំពិភាក្សា និងផ្តល់យោបល់ក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ប្រព័ន្ធបៀវត្ស តាមការចាំបាច់។

ប្រធានក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្សអាចផ្តួចផ្តើមគំនិតស្នើដល់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបង្កើតអនុក្រុមការងារដើម្បីពិនិត្យ និងសិក្សាលើស្ថានភាពជាក់លាក់ណាមួយដែលជាជំនួយដល់ការងារកែទម្រង់ប្រព័ន្ធបៀវត្ស ។

**ប្រការ៧.-**

ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្សអាចប្រើប្រាស់មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សម្រាប់បំពេញការងារបន្ថែមលើសមាសភាពដែលបានកំណត់ក្នុងសេចក្តីសម្រេចនេះ។ ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្សក៏អាចប្រើប្រាស់ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិដើម្បីជួយដល់ក្រុមការងារបន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨.-**

សេចក្តីសម្រេចរាជរដ្ឋាភិបាលកម្ពុជា លេខ ១៦ សសរ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារកំណែទម្រង់ប្រព័ន្ធបៀវត្ស ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ, រដ្ឋមន្ត្រី,រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៩
- -រាជកិច្ច
- -ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០៥៩ ..... សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និង រដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់ក្នុងការធានាការដឹកនាំឱ្យបានល្អ និងប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចដែលរាជរដ្ឋាភិបាលនិងស្ថាប័ននីតិប្បញ្ញត្តិប្រគល់ជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការឱ្យទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភាលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ១: កំណត់ភារកិច្ចតាមក្របខ័ណ្ឌការងារជូនថ្នាក់ដឹកនាំក្រសួងដូចតទៅ :**

**ក.** បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធានស្ថាប័ន ទទួលបន្ទុកដឹកនាំគ្រប់គ្រងការងាររួមទាំងអស់របស់ក្រសួង ជាពិសេស ដឹកនាំត្រួតពិនិត្យនិងតាមដាន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល លើរាល់ចំណុចដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទទួលបន្ទុកដោយឡែក ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងការគ្រប់គ្រងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋាន រតនាគារជាតិ អគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង និង ការងារចាត់តាំងបុគ្គលិក ព្រមទាំងជាទេសាភិបាលកម្ពុជាប្រចាំធនាគារ ពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី និង ជារដ្ឋមន្ត្រីហិរញ្ញវត្ថុកម្ពុជា នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រី ហិរញ្ញវត្ថុអាស៊ាន ។

ខ. ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខ័ណ្ឌការងារ ដូចខាងក្រោមៈ

១- គោលនយោបាយៈ សម្របសម្រួលគោលនយោបាយចំណាយ និងកិច្ចការសហប្រតិបត្តិការ អន្តរជាតិ ។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋាន គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ។

៣- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ព្រឹទ្ធសភា រដ្ឋសភា និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៤- ការងារដោយឡែកៈ ជាទេសាភិបាលកម្ពុជាជំនួសប្រចាំធនាគារពិភពលោក និង ធនាគារ អភិវឌ្ឍន៍អាស៊ី ជាតំណាងកម្ពុជាក្នុងក្រុមប្រឹក្សាពាណិជ្ជកម្មសេរីអាស៊ាន (AFTA Council) និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

គ. ឯកឧត្តម **ជុំ វិជិត្ត** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខ័ណ្ឌការងារ ដូចខាងក្រោមៈ

១- គោលនយោបាយៈ សម្របសម្រួលគោលនយោបាយចំណូល ។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ។

៣- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

៤- ការងារដោយឡែកៈ ជួយពិនិត្យ និង ផ្តល់យោបល់ជូនរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានពន្ធដារ និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ឃ.** លោកជំទាវ **ខួន សុខា** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខ័ណ្ឌការងារ ដូចខាងក្រោមៈ

១- គោលនយោបាយៈ សម្របសម្រួលគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

៣- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងផែនការ, ក្រសួងសុខាភិបាល និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

៤- ការងារដោយឡែកៈ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងគណៈកម្មការមូលបត្រកម្ពុជា និង ជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ង.** ឯកឧត្តម **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខ័ណ្ឌការងារ ដូចខាងក្រោមៈ

១- គោលនយោបាយៈ សម្របសម្រួលគោលនយោបាយអភិវឌ្ឍវិស័យឯកជន ។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់នាយកដ្ឋានពាក់ព័ន្ធចំណុះអគ្គលេខាធិការដ្ឋាន ក្រៅពីការងារចាត់តាំង ។ ដោយឡែក ក្នុងការអនុវត្តការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍សហប្រតិបត្តិការ ចំពោះគម្រោងអភិវឌ្ឍដែលមានការពាក់ព័ន្ធនឹងដៃគូ សហប្រតិបត្តិការ គឺត្រូវពិភាក្សាជាមួយឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការសហប្រតិបត្តិការ ដើម្បីរួមគ្នាដោះស្រាយ ឱ្យការងារប្រព្រឹត្តទៅដោយរលូន ។

៣- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងព្រះបរមរាជវាំង, ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងអភិវឌ្ឍន៍ជនបទ ។

៤- ការងារដោយឡែកៈ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការងារពាក់ព័ន្ធអង្គការពាណិជ្ជកម្មពិភពលោក (WTO), តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ច្រកចេញ-ចូលតែមួយ) និង ជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ច.** ឯកឧត្តម **ឌី តាឃី** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខ័ណ្ឌការងារ ដូចខាងក្រោមៈ

១- គោលនយោបាយៈ សម្របសម្រួលគោលនយោបាយអភិបាលកិច្ចសាជីវកម្ម, គណនេយ្យ, សវនកម្ម និង អធិការកិច្ច ។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង អគ្គាធិការដ្ឋាន ។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង អគ្គាធិការដ្ឋាន ។

៣- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងទេសចរណ៍ ។

៤- ការងារដោយឡែកៈ ដឹកនាំគណៈកម្មាធិការឯកជនភាវូបនីយកម្ម ក្រុមប្រឹក្សាជាតិ គណនេយ្យ, ការងារហ្វ្រង់កូហ្វូនី និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ ប្រធានស្ថាប័ន ។

**ឆ.** ឯកឧត្តម **ជុំ គឹមឡេង** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខ័ណ្ឌការងារដូចខាងក្រោមៈ

១- គោលនយោបាយៈ សម្របសម្រួលគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និង ការគ្រប់គ្រងសាច់ប្រាក់។

២- ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ ការងារប្រមូលចំណូល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

៤- ការងារដោយឡែកៈ ពិនិត្យនិងផ្តល់យោបល់ជូនរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងអគ្គនាយកដ្ឋានរតនាគារជាតិ និង ជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ប្រការ២: អំពីភារកិច្ច និង សិទ្ធិអំណាច**

១. យោងតាមច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ រដ្ឋមន្ត្រីមានភារកិច្ចទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ស្ថាប័ននីតិប្បញ្ញត្តិ លើគ្រប់សកម្មភាពការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយធ្វើការពិនិត្យ សំរេចចុងក្រោយលើរាល់ការងារ និង ចុះហត្ថលេខាលើលិខិតផ្ញើជូនស្ថាប័ននីតិប្បញ្ញត្តិ និងគណៈរដ្ឋមន្ត្រី ទៅតាមច្បាប់ជាធរមាន ។

ចំពោះការងារធំៗ រដ្ឋមន្ត្រី ត្រូវពិភាក្សាជាមួយរដ្ឋលេខាធិការជាមុន មុននឹងជ្រើសរើសយកការសំរេចជាចុងក្រោយ ។

២. រដ្ឋលេខាធិការ ទទួលដឹកនាំការងារតាមក្រសួង ស្ថាប័ន និង តាមចង្កោមទទួលបន្ទុកដែលបានប្រគល់ជូន និង ផ្តល់យោបល់ជូនរដ្ឋមន្ត្រី ពិនិត្យ សំរេចលើរាល់សំណើដែលមានការពាក់ព័ន្ធ ។

៣. រដ្ឋលេខាធិការអាចប្រគល់សិទ្ធិពិនិត្យ និង សម្រេចជូនអនុរដ្ឋលេខាធិការ នូវការងារដែលស្ថិតក្នុងចង្កោមការងាររបស់ខ្លួន បន្ទាប់ពីមានការសម្រេចយល់ព្រមរបស់រដ្ឋមន្ត្រី ។

៤. ក្នុងពេលរដ្ឋលេខាធិការអវត្តមានដោយជាប់បំពេញបេសកកម្មក្រៅប្រទេស ដើម្បីធានានិរន្តភាពការងារ រដ្ឋលេខាធិការត្រូវលើកសំណើសុំការសម្រេចរបស់រដ្ឋមន្ត្រី ផ្ទេរសិទ្ធជូនរដ្ឋលេខាធិការមួយរូបទៀត ឱ្យបំពេញការងារជំនួសរហូតដល់ចូលបំពេញការងារវិញ។

**ប្រការ៣ : អំពីនីតិវិធី និងរបៀបរបបបំពេញការងារប្រចាំថ្ងៃ**

១. រាល់សំណុំឯកសារដែលត្រូវដាក់សុំការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំជាកំណត់បង្ហាញសង្ខេបរឿងតាមឋានានុក្រមការងារនៃមតិអង្គភាពជំនាញ មតិការិយាល័យជំនាញ មតិប្រធាននាយកដ្ឋាន- មតិអគ្គនាយក- ឬមតិអគ្គលេខាធិការ- មតិអនុរដ្ឋលេខាធិការ- មតិរដ្ឋលេខាធិការ និង មតិសំរេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមគំរូបោះពុម្ពនៃកំណត់បង្ហាញ ដែលបានប្រើប្រាស់កន្លងមកដោយមានកាលបរិច្ឆេទចូលចេញ និង មានមូលវិចារណ៍ច្បាស់លាស់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។ នៅក្នុងការបំពេញការងារផ្សេងៗ ស្របតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី ក្នុងករណីដែលមានការងារជាក់ស្តែងណាមួយមានការពាក់ព័ន្ធគ្នាតាមខ្សែទទឹង អនុរដ្ឋលេខាធិការឬរដ្ឋលេខាធិការនីមួយៗ ត្រូវពិគ្រោះយោបល់ជាមួយអនុរដ្ឋលេខាធិការ ឬរដ្ឋលេខាធិការដែលមានការពាក់ព័ន្ធ ដើម្បីត្រៀមយោបល់ និងជម្រើសនានារួមគ្នា សម្រាប់ការសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រី ។ ក្នុងករណីចាំបាច់ គឺអាចស្នើសុំរដ្ឋមន្ត្រីដឹកនាំប្រជុំចង្អៀតក្នុងចំណោមថ្នាក់ដឹកនាំដែលមានការពាក់ព័ន្ធ ដើម្បីសម្រេចការងារនោះ ។

២. អំពីរបបប្រជុំ:

- ប្រជុំថ្នាក់ដឹកនាំក្រសួងៈ ជាគោលការណ៍ នៅរៀងរាល់សប្តាហ៍នីមួយៗ នឹងមានការប្រជុំថ្នាក់ដឹកនាំក្រសួងប្រចាំសប្តាហ៍ ហើយអាចនឹងមានការប្រជុំវិសាមញ្ញ តាមការចាំបាច់នៃការងារ ។ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ត្រូវចូលរួមប្រជុំដើម្បីពិភាក្សាបូកសរុបនិងដោះស្រាយការងាររួមនិងកែលំអចំណុចខ្វះខាត ។ ក្នុងករណីចាំបាច់ អាចអញ្ជើញអគ្គលេខាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន និង អង្គភាពចំណុះក្រសួងដើម្បីចូលរួម ។

- ប្រជុំថ្នាក់អគ្គនាយកដ្ឋានៈ នៅរៀងរាល់ខែនីមួយៗ អគ្គនាយកដ្ឋានត្រូវរៀបចំឱ្យមានការប្រជុំប្រចាំខែ ដើម្បីបូកសរុបអំពីសកម្មភាព និង លទ្ធផលការងារប្រចាំខែ និង ដើម្បីលើកវិធានការដោះស្រាយ ព្រមទាំងកំណត់ទិសដៅការងារដែលត្រូវធ្វើបន្តទៅថ្ងៃមុខ ។

- ប្រជុំថ្នាក់នាយកដ្ឋានៈ រៀងរាល់ពីរសប្តាហ៍ នាយកដ្ឋានត្រូវរៀបចំឱ្យមានការប្រជុំផ្ទៃក្នុងនាយកដ្ឋានរបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់អង្គភាព។

- អគ្គនាយកដ្ឋាន និង នាយកដ្ឋាន ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការប្រជុំតាមការកំណត់ខាងលើជូនរដ្ឋមន្ត្រី និង ថ្នាក់ដឹកនាំក្រសួងដែលមានការពាក់ព័ន្ធ ជ្រាប និង ផ្តល់ការណែនាំ ។

ក្នុងករណីរដ្ឋមន្ត្រីអវត្តមាន ដោយជាប់បំពេញបេសកកម្មក្រៅប្រទេស រដ្ឋមន្ត្រីនឹងលើកសំណើគោរពជូនសម្តេចនាយករដ្ឋមន្ត្រី សូមតែងតាំងរដ្ឋលេខាធិការ មួយរូប ទទួលចាត់ចែងការងារជំនួសរដ្ឋមន្ត្រី ក្នុងឋានៈជា រដ្ឋមន្ត្រីស្តីទី ។ រដ្ឋមន្ត្រីស្តីទី ត្រូវចាត់ចែងការងារស្របតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី បន្ទាប់ពីមានការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីស្តីទីត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីជ្រាប ពីសកម្មភាពការងារ និង ការសំរេចដែលមានលក្ខណៈបន្ទាន់នានាដែលបានធ្វើឡើងក្នុងរយៈពេលទទួលការប្រគល់សិទ្ធិកន្លងមក ។

**ប្រការ៤:** ប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥ :** ក្នុងករណីចាំបាច់ ប្រកាសនេះអាចត្រូវបានកែសម្រួលទៅតាមសភាពការណ៍ជាក់ស្តែង ។

**ប្រការ៦.-** រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ ដែលមានរាយនាមក្នុងប្រការ១ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គលេខាធិការ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន និង គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តន៍តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៦"ដើម្បីអនុវត្តន៍"
- ឯកសារ- កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១: ការគ្រប់គ្រងថវិកាក្រសួង-ស្ថាប័ន
## នៃប្រកាសលេខ ១០៤៩ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣

### កំណត់បង្ហាញរឿង

លិខិតលេខ: ................ថ្ងៃទី ..... ខែ ......ឆ្នាំ ...... របស់ ..............................

កម្មវត្ថុ:..........................................................................................

ខ្លឹមសារសង្ខេប:..................................................................................

**យោបល់ការិយាល័យជំនាញ**

(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់នាយកដ្ឋានជំនាញ:**

(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់អគ្គនាយកដ្ឋាន/អគ្គលេខាធិការដ្ឋាន**

(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់ ឯ.ឧ. អនុរដ្ឋលេខាធិការ ឬរដ្ឋលេខាធិការ ទទួលបន្ទុកក្រសួង-ស្ថាប័ន**

(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់ ឯ.ឧ រដ្ឋលេខាធិការទទួលបន្ទុកបច្ចេកទេស**

(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**ការសំរេចរបស់ ឯ.ឧ. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

## ឧបសម្ព័ន្ធទី ២ : ការគ្រប់គ្រងកិច្ចការបច្ចេកទេស
## នៃប្រកាសលេខ ១០៤៩ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣

### កំណត់បង្ហាញរឿង

**កម្មវត្ថុ:**..........................................................................................................................

**យោង:**..........................................................................................................................

**យោបល់ការិយាល័យជំនាញ**(មិនលើសពី ម៉ោង)
(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**នាយកដ្ឋានជំនាញ** (មិនលើសពី ម៉ោង)
(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់អគ្គនាយកដ្ឋាន/អគ្គលេខាធិការដ្ឋាន**(មិនលើសពី ម៉ោង)
(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់ឯ.ឧ. អនុរដ្ឋលេខាធិការ:**(មិនលើសពី ម៉ោង)
(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**យោបល់រដ្ឋលេខាធិការ:**(មិនលើសពី ម៉ោង)
(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**ការសំរេចរបស់ ឯ.ឧ. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
(ចូលថ្ងៃទី ខែ ឆ្នាំ ម៉ោង ចេញថ្ងៃទី ខែ ឆ្នាំ ម៉ោង )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៥១ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការចម្រុះ ទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹតលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** បង្កើតគណៈកម្មការចម្រុះមួយក្រុម ដោយមានសមាសភាពមកពីៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុវជននិងយុវនីតិសម្បទា និងធនាគារជាតិនៃកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម **ជូ គីមឡេង** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ខង្យ ម៉ឹនឥន្ទ្រាខុច** | អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម **យក់ ម៉ីនណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៤- ឯកឧត្តម **ឡើម សុគន្ធ** | អនុរដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥- លោកជំទាវវេជ្ជបណ្ឌិត **យក់ សម្បត្តិ** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| ៦- ឯកឧត្តម **ថោង មុំរ៉ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជននិងកីឡា | សមាជិក |

៧- ឧត្តមសេនីយ៍ទោ **សុខ ចណ្ណារ៉ា** អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងការពារជាតិ សមាជិក

៨- ឯកឧត្តម **សេង យូអ៊ាន់** អគ្គនាយករងនិងជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ផ្នែករដ្ឋបាលស៊ីវិល) នៃក្រសួងមហាផ្ទៃ សមាជិក

៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា ចន្ថា** ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ផ្នែកសន្តិសុខសាធារណៈ) នៃក្រសួងមហាផ្ទៃ សមាជិក

១០- លោកស្រី **គាំ គណ្ណា** ប្រធាននាយកដ្ឋានប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា សមាជិក

**ប្រការ ២**: គណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សិក្សា និងរៀបចំផែនការសកម្មភាពគ្រប់ជ្រុងជ្រោយនិងជាជំហានៗ ព្រមទាំងកំណត់ពេលវេលាអនុវត្ត ដើម្បីជានាការអនុវត្តដោយរលូន និងសម្រេចឲ្យបានលទ្ធផលចុងក្រោយតាមការគ្រោងទុក គឺការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការទាំងអស់តាមប្រព័ន្ធធនាគារ
- សម្របសម្រួលជាមួយធនាគារជាដៃគូ ក្នុងការរៀបចំអនុស្សរណៈនៃការយោគយល់គ្នាមួយ ស្តីពីកិច្ចដំណើរការ នៃកិច្ចប្រតិបត្តិការសេវាប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- ផ្សព្វផ្សាយជូនមន្ត្រីរាជការទូទាំងប្រទេស ដើម្បីឲ្យអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- រៀបចំយន្តការដោះស្រាយបញ្ហាបច្ចេកទេសនិងសម្រួលដល់ការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- ត្រូវប្រជុំពិភាក្សា ដើម្បីស្វែងរកការឯកភាពគ្នានូវរាល់កិច្ចការទាំងឡាយ មុនដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងសម្រេច។

**ប្រការ ៣**: អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីខ្លួន ដូចប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- រាជកិច្ច "ដើម្បីផ្សព្វផ្សាយ"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០៥២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិចុះហត្ថលេខា ជាអណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ លើអាណត្តិបើកប្រាក់ ចំណាយឥណទានថវិកាជំពូក ២១

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០៤៩ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០៥០ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ ៖** ប្រគល់សិទ្ធិជូន ឯកឧត្តមរដ្ឋលេខាធិការ **វង្សី វិស្សុត** ចុះហត្ថលេខា ជាអណាប័កផ្ទេរសិទ្ធិ លើអាណត្តិបើកប្រាក់ចំណាយឥណទានថវិកាជំពូក ២១ ដោយមិនកំណត់ចំនួនទឹកប្រាក់។

**ប្រការ ២ ៖** ប្រគល់សិទ្ធិចុះហត្ថលេខា ជាអភិបាលហិរញ្ញវត្ថុ លើអាណត្តិបើកប្រាក់ចំណាយឥណទានថវិកាជំពូក ២១ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

១-ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការ ចុះហត្ថលេខាជាអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់ ដែលមានទឹកប្រាក់ចាប់ពី ២.០០០ លានរៀលឡើង។

២-ឯកឧត្តម **ហែម វណ្ណឌី** អនុរដ្ឋលេខាធិការ ចុះហត្ថលេខាជាអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់ ដែលមានទឹកប្រាក់ចាប់ពី ៥០០ លានរៀល ដល់ក្រោម ២.០០០ លានរៀល។

៣-ឯកឧត្តម **ចាន់ សុធី** អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ចុះហត្ថលេខាជាអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់ ដែលមានទឹកប្រាក់ក្រោម ៥០០ លានរៀល។

**ប្រការ ៣ ៖** ប្រគល់សិទ្ធិជូន ឯកឧត្តមរដ្ឋលេខាធិការ **វង្សី វិស្សុត** ពិនិត្យផ្តល់គោលការណ៍ និងចុះហត្ថលេខាលើលិខិតជានាចំណាយ ជំពូក ២១ ដែលមានទឹកប្រាក់ក្រោម ២.០០០ លានរៀល។ ចំពោះគោលការណ៍ជានាចំណាយ ដែលមានទឹកប្រាក់ចាប់ពី ២.០០០ លានរៀលឡើង **រដ្ឋមន្ត្រី** រក្សាសិទ្ធិសម្រេច និងចុះហត្ថលេខាដដែល។

**ប្រការ ៤ ៖** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ ៖** នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- រាជកិច្ច
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៥៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១៣

## ប្រកាស
## ស្តីពីការបន្ថែមឥណទានថវិកា
## ជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- យោងលិខិតលេខ ៩៩/១៣ មកបវ/ពហ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ និងលិខិតលេខ១២៦១ កប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១:** ដោយអនុលោមទៅតាមមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានអនុញ្ញាត ឱ្យបំពេញបន្ថែមឥណទានថវិកាជំពូក ៦៤ (បន្ទុកបុគ្គលិក) ចំនួន ១៦៩.៣៩៦.០០០ រៀល (មួយរយហុកសិបប្រាំបួនលានបីរយកៅសិបប្រាំមួយពាន់រៀលគត់)ជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ ដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា:ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានដើមឆ្នាំ | ឥណទានបច្ចុប្បន្ន | ឥណទាន បំពេញបន្ថែម | ឥណទានថ្មី ក្រោយបំពេញបន្ថែម |
|---|---|---|---|---|---|---|---|
| | | | បន្ថែមឥណទានជំពូក៦៤ | | | 169.396 | |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 247.500 | 247.500 | 138.796 | 386.296 |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 80.000 | 80.000 | 25.100 | 105.100 |
| 64 | 642 | 6424 | ប្រាក់កម្រៃគរុកោសល្យ | 5.000 | 5.000 | 5.500 | 10.500 |

**ប្រការ២:** ឥណទានដែលបានបន្ថែមក្នុងប្រការ ១ ខាងលើត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជជីវៈខេត្តព្រះវិហារសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ ដើម្បីបំពេញបន្ថែមលើបៀវត្សមូលដ្ឋានប្រាក់បំណាច់មុខងារ និង ប្រាក់កម្រៃគរុកោសល្យ ឆ្នាំ ២០១៣ ។

**ប្រការ៣:** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមអភិបាលខេត្តព្រះវិហារ ជាអ្នកទទួលបន្ទុកអនុវត្តប្រកានេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត.អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន</u>

- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះវិហារ
- រតនាគារខេត្តព្រះវិហារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៥៥ សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៣

# ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ១០១៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ៩១៦ លស អរហ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងទេសចរណ៍

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងទេសចរណ៍ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកា ដូចមានបញ្ជាក់ខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ឆ្នាំ២០១៣ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក 64** | **342.400** | **342.400** | **61.400** | **61.400** | **342.400** |
| 64 | 643 | 6432 | ប្រាក់បំណាច់សម្រាប់ប្រឡង និងប្រឡងប្រជែង | 15.000 | 15.000 | - | 3.400 | 11.600 |
| 64 | 643 | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ | 5.000 | 5.000 | - | 5.000 | - |
| 64 | 645 | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 36.000 | 36.000 | - | 20.000 | 16.000 |
| 64 | 645 | 6453 | មរណភាព | 5.000 | 5.000 | - | 1.000 | 4.000 |
| 64 | 645 | 6454 | ឧបត្ថម្ភនិវត្តជន | 24.000 | 24.000 | - | 7.000 | 17.000 |
| 64 | 645 | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | 28.000 | 28.000 | - | 20.000 | 8.000 |
| 64 | 645 | 6456 | គ្រោះថ្នាក់ក្នុងការងារ និងទុព្វលភាព | 3.000 | 3.000 | - | 3.000 | - |
| 64 | 645 | 6457 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ | 2.000 | 2.000 | - | 2.000 | - |
| 64 | 641 | 6416 | លាភការទីប្រឹក្សា | 162.000 | 162.000 | 48.000 | - | 210.000 |
| 64 | 641 | 6418 | លាភការអ្នកជំនួយការ | 62.400 | 62.400 | 13.400 | - | 75.800 |

**ប្រការ២ :** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាអ្នកទទួលបន្ទុកអនុវត្ត ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត.អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៥៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣

## ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/១២១២/០១០ , ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក , ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក , ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក , ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨សហវ.ប្រក , ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ២០៩៤លស, ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្ងង់ថវិកា របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកា ដូចមានបញ្ជាក់ខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក ៦៤** | | | **2.975.900** | **2.975.900** | |
| 64 | 641 | 6416 | លាភការទីប្រឹក្សា | 1.181.000 | 1.283.625 | - | 8.000 | 1.275.625 |
| 64 | 642 | 6426 | ប្រាក់បំណាច់តំបន់ | 396.000 | 396.000 | - | 56.000 | 340.000 |
| 64 | 643 | 6433 | រង្វាន់ | 1.500.000 | 1.500.000 | - | 138.000 | 1.362.000 |
| 64 | 643 | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេង | 50.000 | 50.000 | - | 50.000 | - |
| 64 | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | 6.795.000 | 6.795.000 | - | 151.000 | 6.644.000 |
| | | | កូនមានអាយុតិចជាង ១៥ឆ្នាំ | 4.342.000 | 4.342.000 | - | 98.000 | 4.244.000 |
| | | | កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ | 83.000 | 83.000 | - | 15.000 | 68.000 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 2.370.000 | 2.370.000 | - | 38.000 | 2.332.000 |
| 64 | 645 | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 41.000 | 41.000 | - | 40.000 | 1.000 |
| 64 | 645 | 6453 | មរណភាព | 3.419.000 | 3.419.000 | - | 2.122.000 | 1.297.000 |
| 64 | 645 | 6454 | ឧបត្ថម្ភនិវត្តជន | 2.642.000 | 2.642.000 | - | 21.000 | 2.621.000 |
| 64 | 645 | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | 59.000 | 59.000 | - | 37.000 | 22.000 |
| 64 | 645 | 6456 | គ្រោះថ្នាក់ក្នុងការងារ និងទព្វលភាព | 368.000 | 368.000 | - | 352.900 | 15.100 |
| 64 | 642 | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម | 2.342.000 | 2.342.000 | 2.008.665 | - | 4.350.665 |
| 64 | 642 | 6425 | ប្រាក់បំប៉នជីវភាពពិសេស | 88.731.000 | 90.810.599 | 967.235 | - | 91.777.834 |

**ប្រការ២:** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត.អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៥៥ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣

## ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- យោងលិខិតលេខ៣៨៧/០១៣ សអយ,ពហ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៣ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តព្រះវិហារ និងលិខិតលេខ ១៩៥០ស.អ.យ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រះវិហារនៃក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា:ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានដើមឆ្នាំ | ឥណទានបច្ចុប្បន្ន | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | ការធ្វើនិយ័តកម្មផ្ទៃក្នុងជំពូក ៦៤ | | | 12.000 | 12.000 | |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 75.000 | 75.000 | - | 7.000 | 68.000 |
| 64 | 644 | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 43.000 | 43.000 | - | 5.000 | 38.000 |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 130.000 | 130.000 | 6.900 | - | 136.900 |
| 64 | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | - | - | 5.100 | - | 5.100 |

**ប្រការ២:** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ឯកឧត្តមអភិបាលខេត្តព្រះវិហារជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត.អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះវិហារ
- រតនាគារខេត្តព្រះវិហារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ